# ខ្លឹមសារសង្ខេបអត្ថបទ
# ការជូនដំណឹងក្នុងពេលឃាត់ខ្លួន

Johann Bair, The International Covenant on Civil and Political Rights and Its (First) Optional Protocol, A Short Commentary Based on Views, General Comments and Concluding Observations by the Human Rights Committee, pp. 37-38, 2005

**បទប្បញ្ញត្តិ៖** មាត្រា ៩(២) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ៖ *ជនណាដែលត្រូវបានចាប់ខ្លួន ត្រូវមានសិទ្ធិឲ្យគេប្រាប់ឲ្យដឹងនៅពេលចាប់ខ្លួន អំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឲ្យដឹងភ្លាម អំពីការចោទប្រកាន់។*

១. ក្នុងពេលអំឡុងឃាត់ខ្លួន ជនសង្ស័យ មានសិទ្ធិទទួលបានការជូនដំណឹង អំពីមូលហេតុ នៃការឃាត់ខ្លួន ជាភាសាដែលគាត់អាចយល់បាន (សម្រាប់ជនបរទេស ឬជនភាគតិច...)។ ការជូនដំណឹងនេះត្រូវធ្វើឡើងភ្លាមៗ ដើម្បីជាជំហានសម្រាប់ជនសង្ស័យ ត្រៀមលក្ខណៈការពារខ្លួន សុំដោះលែងប្រសិនបើមូលហេតុ នៃការឃាត់ខ្លួន គ្មានមូលដ្ឋានជាដើម។ ខ្លឹមសារនៃការជូនដំណឹងត្រូវតែគ្រប់គ្រាន់ ដូចជាខ្លឹមសារនៃបណ្តឹងចោទប្រឆាំងគាត់ ក៏ប៉ុន្តែ វាមិនទាមទារឲ្យលម្អិតទេ។

២. ក្នុងករណីជនសង្ស័យជាជនបរទេស ឬមានមេធាវី បែបបទរបស់នគរបាល ត្រូវបានផ្អាកដើម្បីរង់ចាំវត្តមាននៃអ្នកបកប្រែ ឬ មេធាវី។ ការជូនដំណឹង ដោយគ្មានវត្តមាននៃអ្នកបកប្រែ គេមិនអាចនិយាយថា មិនសមហេតុផលទាំងស្រុង ថាបុគ្គលនោះមិនបានដឹងអំពីមូលហេតុនៃការឃាត់ខ្លួនទេ។

៣. ពាក្យថា «ភ្លាមៗ» (promptly) មិនត្រូវបានកំណត់ទេ។ ទោះបីជាយ៉ាងនេះក្តី ប្រសិនបើមានរយៈពេលយូរពេក អាចនឹងនាំឲ្យមានការបំពានមាត្រានេះ។ ជាក់ស្តែង ក្នុងអំឡុងពេល ៥០ ម៉ោងនៃការឃាត់ខ្លួន ហេតុផលនៃការឃាត់ខ្លួន មិនត្រូវបានផ្តល់ជូន នេះជាការបំពានមាត្រា ៩(២) បើទោះបីក្រោយមក គាត់ត្រូវបានដោះលែង។ កង្វះថវិកា សម្រាប់ដំណើរការរដ្ឋបាលយុត្តិធម៌សមស្រប មិនពាក់ព័ន្ធនិងមិនមែនជាយុត្តិកម្ម ដែលទទួលយកបាន សម្រាប់ដោះសារការបំពានមាត្រានេះទេ។

៤. វាមិននាំឲ្យអាជ្ញាធររួចពីកាតព្វកិច្ចជូនដំណឹង ដោយគ្រាន់តែអះអាងថា ជនសង្ស័យទំនងជាបានដឹងអំពីមូលហេតុនៃការឃាត់ខ្លួន។ ទោះបីយ៉ាងនេះក្តី ការណ៍ដែលជនសង្ស័យ បានប្រគល់ខ្លួន អាជ្ញាធរ មិនចាំបាច់ជូនដំណឹងអំពីមូលហេតុនៃការឃាត់ខ្លួនទេ។

**ពាក្យគន្លឹះ៖** អ្នកបកប្រែ, វត្តមាននៃមេធាវី, ពាក្យ promptly។